# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៩៤ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការរៀបចំអង្គកឋិនទានដង្ហែទៅកាន់វត្តខ្មែរក្រោម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតគណៈកម្មការរៀបចំអង្គកឋិនទានដង្ហែទៅកាន់វត្តខ្មែរក្រោម ដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១- សម្តេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** | ប្រធាន |
| ២- ឯកឧត្តម **ឈិន កេតនា** | អនុប្រធានអចិន្ត្រៃយ៍ |
| ៣- លោកជំទាវបណ្ឌិតសភាចារ្យ **ភឿង សកុណា** | អនុប្រធាន |
| ៤- ឯកឧត្តម **ចាយ បូរិន** | អនុប្រធាន |
| ៥- ឯកឧត្តម **នេត្រ ភក្ត្រា** | អនុប្រធាន |

| | |
|---|---|
| ៦- ឯកឧត្តម **ម៉ម សារិន** | សមាជិក |
| ៧- ឯកឧត្តម **សំហោង មុរស** | សមាជិក |
| ៨- ឯកឧត្តម **ខៀវ កាញារីទ្ធ** | សមាជិក |
| ៩- លោកជំទាវ **អ៊ុក ម៉ាលី** | សមាជិកា |
| ១០- ឯកឧត្តម **សាន សាង** | សមាជិក |
| ១១- ឯកឧត្តម **សេង ឡៀង** | សមាជិក |
| ១២- ឯកឧត្តម **ចាន់ សុធី** | សមាជិក |
| ១៣-ឯកឧត្តម **ឃី សុវណ្ណរតនា** | សមាជិក |
| ១៤- លោកជំទាវ **មឿង ស៊ាងសេង** | សមាជិកា |
| ១៥- ឯកឧត្តម **ស៊ុយ សាន** | សមាជិក |
| ១៦- ឯកឧត្តម **ប៉ាក់ សុខុម** | សមាជិក |
| ១៧- ឯកឧត្តម **មាស រដ្ឋា** | សមាជិក |
| ១៨- ឯកឧត្តម **ឃួងស្រេង** | សមាជិក |
| ១៩- ឯកឧត្តម **គួច ចំរើន** | សមាជិក |
| ២០- ឯកឧត្តម **ឌី សំណាង** | សមាជិក |
| ២១- ឧត្តមសេនីយ៍ឯក **ដៀង សារុន** | សមាជិក |
| ២២- ឧត្តមសេនីយ៍ទោ **សែ ធុទ្ធី** | សមាជិក។ |

**ប្រការ២ ._**

គណៈកម្មការនេះ មានភារកិច្ចដូចតទៅ៖

- ដឹកនាំ ចាត់តាំង និងរៀបចំអង្គកឋិនទានដង្ហែទៅកាន់វត្តខ្មែរក្រោម ឱ្យប្រព្រឹត្តទៅស្របតាមប្រពៃណីទំនៀមទម្លាប់ ព្រះពុទ្ធសាសនា
- ពិនិត្យនិងលើកសំណើដោះស្រាយបញ្ហានានាទាក់ទងនឹងការរៀបចំអង្គកឋិនទាន ឱ្យប្រព្រឹត្តទៅបានល្អប្រសើរ
- ធ្វើលិខិតអញ្ជើញនិងរៀបចំទទួលបដិសណ្ឋារកិច្ចថ្នាក់ដឹកនាំនិងភ្ញៀវដែលអញ្ជើញចូលរួម
- លើកគម្រោងនិងចាត់ចែងគ្រប់គ្រងចំណូល ចំណាយថវិកាពីប្រភពនានា
- អនុវត្តភារកិច្ចផ្សេងទៀតតាមការចាំបាច់សម្រាប់បម្រើឱ្យការរៀបចំអង្គកឋិនទាន។

**ប្រការ៣ ._**

អនុប្រធានអចិន្ត្រៃយ៍ អនុប្រធាន និងសមាជិក នៃគណៈកម្មការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

គណៈកម្មការនេះ មានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ចូលរួមប្រជុំ តាមការចាំបាច់។

**ប្រការ៤ .-**

គណៈកម្មការនេះ អាចបង្កើតអនុគណៈកម្មការនិងក្រុមការងារបន្ថែមជាជំនួយការ និងប្រើប្រាស់មន្ត្រីក្រោមឱវាទតាមការចាំបាច់ ដើម្បីជានាឱ្យការរៀបចំអង្គកឋិនទានដង្ហែទៅកាន់វត្តខ្មែរក្រោម ប្រព្រឹត្តទៅស្របតាមប្រពៃណី ទំនៀមទម្លាប់ ព្រះពុទ្ធសាសនា។

**ប្រការ៥ .-**

គណៈកម្មការនេះ មានសិទ្ធិប្រើត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី សម្រាប់ដំណើរការការងាររបស់ខ្លួន។

**ប្រការ៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ១៥រោច ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែតុលា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ